វិទ្យាស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអូស្រ្តាលី
THE AUSTRALIAN INSTITUTE FOR SCIENCE AND TECHNOLOGY

សាលារៀន អន្តរជាតិអូស្ត្រាលី
The Australian International School

ណេក្រីសាលារៀន ណេក្រី អន្តរជាតិ
NEKRY International School

វិទ្យាស្ថាន វិទ្យាសាស្ត្រអាស៊ី
THE ASIA INSTITUTE OF SCIENCES

# វេយ្យាករណ៍ អង់គ្លេស-ខ្មែរ

# English-Khmer Grammar

Adjectives
Adverbs
Nouns
VERBS
Pronouns

រៀបរៀងដោយ បណ្ឌិត **យុន សូគ្រីន**

ហាមថតចំលងយកប្រើប្រាស់ជាអាជីវកម្ម ដោយពុំមានការអនុញ្ញាត

# វិទ្យាស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអូស្ត្រាលី

THE AUSTRALIAN INSTITUTE FOR SCIENCE AND TECHNOLOGY

ផ្តល់អាហារូបករណ៍
១០០%
គ្រប់ឆ្នាំសិក្សា

## សិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ បរិញ្ញាបត្រ និង បរិញ្ញាបត្ររង

- ភាសាអង់គ្លេស
- គណនេយ្យនិងធនាគារ
- ការគ្រប់គ្រងនិងអាជីវកម្ម
- ការអប់រំ
- ច្បាប់
- វិទ្យាសាស្ត្រកុំព្យូទ័រ
- វិស្វកម្មនិងស្ថាបត្យកម្ម
- មុខជំនាញជាច្រើនទៀត

និស្សិតចំណាត់ថ្នាក់លេខ 1 នឹងបានអាហារូបករណ៍ធ្វើកម្មសិក្សា នៅប្រទេសអូស្ត្រាលី។

ជាកម្មវិធីសិក្សាល្អបំផុត សម្រាប់អ្នកសិក្សាបណ្តើរ ធ្វើការបណ្តើរៗ

សូមទំនាក់ទំនង: 089 22 32 42 / 086 22 32 42/ 023 65 93 555

www.aist-edu.com aist.cambodia

# វិទ្យាស្ថាន វិទ្យាសាស្ត្រអាស៊ី

## THE ASIA INSTITUTE OF SCIENCES

ឈានមុខក្នុងការបង្រៀនវិជ្ជាពេទ្យ

- តើអ្នកចង់បានអាហារូបករណ៍ ១00% ដើម្បីសិក្សាមុខជំនាញ បរិញ្ញាបត្ររងគិលានុបដ្ឋាក ឆ្មប ឬបច្ចេកទេសមន្ទីរពិសោធន៍ឬទេ?
- តើអ្នកចង់សិក្សាមុខជំនាញជាច្រើនដោយឥតគិតថ្លៃឬទេ?
- វិទ្យាស្ថាននឹងធានាជួយរកការងារជូននិស្សិតធ្វើ



ចាប់ទទួលពាក្យចូលរៀនពីថ្ងៃនេះតទៅ

ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

**010 300 768, 010 300 968, 023 666 8 666**

គេហទំព័រ៖ www.ais-edu.com

# វេយ្យាករណ៍ អង់គ្លេស-ខ្មែរ

# English-Khmer Grammar

**បោះពុម្ពឡើងវិញឆ្នាំ ២០១៧**

រៀបរៀងដោយ **បណ្ឌិត ឃុន សូត្រីន**

ហាមថតចំលងយកប្រើប្រាស់ជាអាជីវកម្ម ដោយពុំមានការអនុញ្ញាត

វិទ្យាស្ថាន វិទ្យាសាស្ត្រអាស៊ី THE ASIA INSTITUTE OF SCIENCES
វិទ្យាស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអូស្ត្រាលី THE AUSTRALIAN INSTITUTE FOR SCIENCE AND TECHNOLOGY
សាលារៀន អន្តរជាតិអូស្ត្រាលី The Australian International School
NEKRY សាលារៀន ណេក្រី អន្តរជាតិ International School

សូមជូនការគោរព ការស្រឡាញ់ និងការដឹងគុណជូនដ៏ជ្រាលជ្រៅបំផុត

**អ្នកម្ដាយ កែវ ប៉ូឡាណេត្រី**

**លោកឪពុក ហ៊ឹម យុន**

**ភរិយា សុខធារី និង កូនស្រី អធិរ័ត្ន ជាទីស្រឡាញ់**

វិទ្យាស្ថាន វិទ្យាសាស្ត្រអាស៊ី
THE ASIA INSTITUTE OF SCIENCES

វិទ្យាស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអូស្ត្រាលី
THE AUSTRALIAN INSTITUTE FOR SCIENCE AND TECHNOLOGY

សាលារៀន អន្តរជាតិអូស្ត្រាលី
The Australian International School

ណេក្រី សាលារៀន ណេក្រី អន្តរជាតិ
NEKRY International School

# អារម្ភកថា

ការរៀបរៀងសៀវភៅវេយ្យាករណ៍អង់គ្លេស-ខ្មែរជាការងារដែលខ្ញុំចូលចិត្តបំផុត ដោយខ្ញុំមានបំណងអោយអ្នកសិក្សាភាសាអង់គ្លេសមានសៀវភៅវេយ្យាករណ៍ល្អត្រឹមត្រូវសម្រាប់រៀននិង ទទួលបានចំណេះដឹងផ្នែកភាសាអង់គ្លេសដែលយើងទាំងអស់គ្នាទទួលស្គាល់ជាមូលដ្ឋានគ្រឹះក្នុងការ ប្រាស្រ័យទាក់ទងក្នុងការងារគ្រប់វិស័យ និង ការសិក្សាទាំងនៅក្នុងស្រុក និង នៅបរទេស។ សៀវភៅវេយ្យាករណ៍អាស៊ី អង់គ្លេស-ខ្មែរត្រូវបានរៀបរៀងឡើង សំរាប់ជួយសំរួលការសិក្សាភាសាអង់គ្លេសរបស់សិស្ស និស្សិត និង អស់លោកនិងលោកស្រីដែលធ្វើការ និង កំពុងសិក្សាភាសាអង់គ្លេស នៅគ្រប់កំរិតចាប់ តាំងពីថ្នាក់ដំបូង កំរិតមធ្យម និង កំរិតខ្ពស់។ ការរៀបរៀងសៀវភៅនេះផ្អែកលើតំរូវការរបស់អ្នកសិក្សាភាសាអង់គ្លេស និង បទពិសោធន៍ខ្ញុំរបស់ក្នុងការងារ និងជាអ្នកបង្រៀនភាសាអង់គ្លេស និងផ្អែកលើសៀវភៅ **Oxford Pocket English Grammar** និពន្ធដោយ **A.J Thomson and A.V Martinez** បោះពុម្ពឆ្នាំ 2001។

ខ្ញុំមានបំណងចែករំលែកបទពិសោធន៍ក្នុងការរៀនភាសាអង់គ្លេសឱ្យបានលទ្ធផលល្អ។ ចំណេះដឹងផ្នែកភាសាអង់គ្លេសជាយានធ្វើឱ្យខ្ញុំទទួលបានអាហារូបករណ៍សិក្សានៅបរទេសនៅពីរសកលវិទ្យាល័យ។ ខ្ញុំបានទទួលអាហារូបករណ៍សិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅសាកលវិទ្យាល័យ The University of Queensland នៅប្រទេសអូស្ត្រាលីនៅឆ្នាំ ១៩៩៩ និង បានទទួលអាហារូបករណ៍សិក្សាថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យ The University of Melbourne នៅប្រទេសអូស្ត្រាលីនៅឆ្នាំ ២០០១ និងជួយឱ្យខ្ញុំបានធ្វើការនៅសាកលវិទ្យាល័យ The Royal Melbourne Institute of Technology និងសាកលវិទ្យាល័យ Monash University នៅប្រទេសអូស្ត្រាលី។

ខ្ញុំសូមបញ្ជាក់ថាការព្យាយាម ការខិតខំសិក្សាដោយខ្លួនឯង និង ការ អនុវត្តន៍ជាមូលដ្ឋានគ្រឹះក្នុងការរៀនភាសាអង់គ្លេសដោយជោគជ័យ។ ខ្ញុំសូមនិយាយប្រាប់ពីដំណើរការរៀនភាសាអង់គ្លេសរបស់ខ្ញុំ។ នៅឆ្នាំ ១៩៨០ អ្នកម្តាយខ្ញុំឈ្មោះ កែវ ប៉ូឡាណេត្រី មានមុខរបរជាគ្រូបង្រៀននៅសាលាបឋមសិក្សាបាក់ទូក និងបានបង្រៀនភាសាអង់គ្លេសដល់ខ្ញុំជាមួយក្មេងជិតខាង។ បន្ទាប់មកខ្ញុំបានរៀនគួរភាសាអង់គ្លេសនៅជាមួយអ្នកគ្រូ និងលោកគ្រូមួយចំនួនទៀតនៅតាមផ្ទះ។ ជូនកាលខ្ញុំទៅរៀន ជូនកាលខ្ញុំឈប់ ហើយខ្ញុំរៀនមិនបានលទ្ធផលល្អប៉ុន្មានទេ ដោយសារខ្ញុំមិនសូវខិតខំប្រឹងប្រែង។ ចាប់ពីឆ្នាំ ១៩៨៨ នៅពេល ខ្ញុំចូលរៀនជាវេជ្ជបណ្ឌិតនៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ខ្ញុំចាប់ផ្តើម រៀនភាសាដោយខ្លួនឯង និង ចាប់ផ្តើមបង្រៀនគួរភាសាអង់គ្លេសនៅពេលយប់នៅសាលាបឋមសិក្សាបាក់ទូក រហូតដល់ឆ្នាំ ១៩៩៤។ ប្រាក់បានពីការបង្រៀនភាសាអង់គ្លេសនេះជាចំណូលដ៏សំខាន់សម្រាប់ការសិក្សាជាវេជ្ជបណ្ឌិតតាំងពីដើមដល់ចប់ ក្នុងរយៈពេល ៦ឆ្នាំ។ ការបង្រៀនគួរនេះ ធ្វើឱ្យខ្ញុំកាន់តែមានចំណេះដឹងផ្នែកភាសាអង់គ្លេស បទពិសោធន៍ និងទំនុកចិត្តលើខ្លួន ធ្វើឱ្យខ្ញុំបានធ្វើជាអ្នកបកប្រែភាសាអង់គ្លេសឱ្យ អ៊ុន តាក់នៅឆ្នាំ ១៩៩៣។ ការបំពេញការងារជាអ្នកប្រែភាសាអង់គ្លេសនេះ ធ្វើឱ្យមានចំណេះដឹងផ្នែកភាសាអង់គ្លេសកាន់ច្រើន និងសន្សំបានប្រាក់បន្តិចបន្តួច អាចឱ្យខ្ញុំបានរៀបរៀង និង បោះពុម្ពវចនានុក្រម សៀវភៅវេយ្យាករណ៍ និង សៀវភៅសិក្សាអង់គ្លេស-ខ្មែរជាច្រើនប្រភេទ ចាប់តាំងពីឆ្នាំ ១៩៩៤ ដល់ ឆ្នាំ ២០០៨។ ខ្ញុំអាចធ្វើបាន អ្នកសិក្សាទាំងឡាយក៏អាចធ្វើបានដែរ។

យើងទាំងអស់គ្នាដឹងថាចំណេះដឹងច្បាស់លាស់ផ្នែកភាសាអង់គ្លេសមានសារៈសំខាន់ជាខ្លាំងសម្រាប់ការសិក្សាទាំងនៅក្នុងប្រទេស និង បរទេស ក៏ដូចជាការបំពេញការងារដោយជោគជ័យ។ ដូច្នេះខ្ញុំចែករំលែកឯកសារអំពីការសិក្សាភាសាអង់គ្លេសរួមមានវចនានុក្រមនិងសៀវភៅវេយ្យាករណ៍ តាម Online ដើម្បីឱ្យអ្នកសិក្សាទាំងឡាយអាចសិក្សាបានគ្រប់ពេល។ សូមចងចាំថា ការព្យាយាម ការខិតខំសិក្សាដោយខ្លួនឯង និង ការអនុវត្តន៍ជាមូលដ្ឋានគ្រឹះក្នុងការរៀនភាសាអង់គ្លេសដោយជោគជ័យ។ វចនានុក្រមនេះជាវចនានុក្រមពេញនិយមបំផុតចាប់តាំងពីការបោះពុម្ពចាប់តាំងពីឆ្នាំ ១៩៩៦។ ពេលនេះ ខ្ញុំសូមដាក់ Online ដើម្បីជូនអ្នកសិក្សាបានប្រើប្រាស់និងរៀនសូត្រ។ ក៏ប៉ុន្តែខ្ញុំសូមហាមប្រាមការថតចំលង និងយកប្រើប្រាស់ជាអាជីវកម្ម ដោយពុំមានការអនុញ្ញាតជាលាយល័ក្សអក្សរពីខ្ញុំ។

ជោគជ័យនៅក្នុងការសិក្សារបស់មនុស្សម្នាក់ៗ ពុំមែនអាស្រ័យតែលើ ប្រាជ្ញាវាងវៃនោះទេ ប៉ុន្តែក៏អាស្រ័យលើការខិតខំប្រឹងប្រែងនិងភាពអត់ធ្មត់របស់ខ្លួន។ មនុស្សម្នាក់ៗមានកំរិតប្រាជ្ញាវាងវៃប្រហាក់ប្រហែលគ្នាប៉ុន្តែកំរិតនៃការខិតខំប្រឹងប្រែងនិងអត់ធ្មត់ជាកត្តាចាំបាច់ក្នុងការកំណត់ពីជោគជ័យក្នុងការសិក្សានិងការងារ។ ការខិតខំប្រឹងប្រែង អត់ធ្មត់ និង ស្រវាស្រទេញជាសម្បត្តិធម្មជាតិបានជាប់មកជាមួយមនុស្សគ្រប់គ្នាពីកំណើត ហើយការប្រើប្រាស់សម្បត្តិធម្មជាតិនេះក្នុងការសិក្សា និងការងារនឹងនាំមកនូវជោគជ័យ ការសំរេច ផលដូចប្រាថ្នា និង អនាគតរុងរឿងសំរាប់មនុស្សគ្រប់រូបជាពិសេសសំរាប់អ្នកក្រីក្រដែលត្រូវការចំណេះដឹងជាមធ្យោបាយសំរាប់រើបំរះចេញពីស្ថានភាពនេះ។ លោក អាល់ប៊ើត អេនស្ទេន ដែលជាកំពូលអ្នកប្រាជ្ញផ្នែករូបវិទ្យា គីមីវិទ្យា និង គណិតវិទ្យាបាន ទូន្មានប្រាប់មនុស្សជំនាន់ក្រោយ អំពីរបៀបទទួលបានជោគជ័យក្នុងការងារ និង ក្នុងជីវិត។ លោកបានពោលថា *ជោគជ័យក្នុងការងារជាផលបូកនៃការខិតខំប្រឹងប្រែងអត់ធ្មត់ និង ចេះរបៀបធ្វើការ*។

ខ្ញុំសូមសំដែងការដឹងគុណ ការគោរព និងការស្រឡាញ់ចំពោះអ្នកម្តាយ កែវ ប៉ូឡាណេត្រី និង លោកឪពុក ហ៊ឹម យុន ដែលបានចិញ្ចឹមបីបាច់ ស្រឡាញ់ថ្នាក់ថ្នមអប់រំ និងលះបង់គ្រប់បែបយ៉ាង ធ្វើឱ្យកូនយល់អំពីតំលៃនៃការសិក្សា សុចរិតភាព ការគោរពស្រឡាញ់ ធ្វើជាមនុស្សល្អ និងមានអនាគតដូចសព្វថ្ងៃនេះ។ កូនចងចាំជានិច្ច និងខិតខំអនុវត្តតាមការអប់រំដ៏ល្អបំផុតរបស់អ្នកម្តាយ និងលោកឪពុកដែលឱ្យកូនជួយស្ត្រី និងកុមារក្រីក្រ និងស្រឡាញ់ប្រទេសជាតិ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរអ្នកសិក្សា និង មនុស្សគ្រប់រូបនូវ សុខភាពល្អនិងការសំរេចបំណងដ៏ឧត្តុង្គឧត្តមដូចប្រាថ្នា។

**បណ្ឌិត យុន សូគ្រីន**
ប្រធានក្រុមប្រឹក្សាធិការ និងនាយក
វិទ្យាស្ថាន វិទ្យាសាស្ត្រអាស៊ី
វិទ្យស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអូស្ត្រាលី
សាលារៀនអន្តរជាតិ អូស្ត្រាលី
សាលារៀន ណេត្រីអន្តរជាតិ
Email: khunsokrin@ais-edu.com

វិទ្យាស្ថាន វិទ្យាសាស្ត្រអាស៊ី THE ASIA INSTITUTE OF SCIENCES | AiST វិទ្យាស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអូស្ត្រាលី THE AUSTRALIAN INSTITUTE FOR SCIENCE AND TECHNOLOGY | សាលារៀន អន្តរជាតិអូស្ត្រាលី The Australian International School | ណេត្រី NEKRY សាលារៀន ណេត្រី អន្តរជាតិ International School

## Session 1: Nouns នាម

### ប្រភេទនិងមុខងារ

**A** ក្នុងភាសាអង់គ្លេស,នាមមានបួនប្រភេទគឺ

- **Common nouns** នាមសាធារណ៍: *dog ឆ្កែ, man បុរស, table តុ*
- **Proper nouns** នាមអសាធារណ៍: *France ប្រទេសបារាំង, Madrid ទីក្រុងម៉ាឌ្រីត, Mrs. Smith អ្នកស្រី Smith, Tom។*
- **Abstract nouns** នាមអរូបី: *beauty សម្ផស្ស, love សេចក្តីស្រឡាញ់,courage សេចក្តីក្លាហាន, fear សេចក្តីតក់ស្លុត, joy ក្តីរីករាយ*
- **Colective nouns** សមូហនាម: crowd ហ្វូងមនុស្ស, flock ហ្វូងសត្វ, group ក្រុម, team ក្រុមមនុស្ស។

**B** នាមអាចដើរតួជា

- ប្រធាន(subject)របស់កិរិយាសព្ទ: *Tomarrived.Tom បានមកដល់។*
- ពាក្យបំពេញន័យ (complement)របស់កិរិយាសព្ទផ្ទាត់ *be, become, seem etc.): Tom is an actor. Tom ជាសិល្បករ។*
- កម្មបទផ្ទាល់(direct object)របស់កិរិយាសព្ទ: *I saw Tom. ខ្ញុំបានជួបTom។*
- កម្មបទប្រយោល(indirect object)របស់កិរិយាសព្ទ: *I gave Tom the book. ខ្ញុំបានជូនសៀវភៅទៅ Tom.*
- កម្មបទរបស់អាយតនិបាត: *I spoke to Tom. ខ្ញុំបាននិយាយជាមួយ Tom។*
- នាមក៏អាចនៅក្នុងករណីម្ចាស់កម្មសិទ្ធិ: *Tom's books. សៀវភៅរបស់ Tom។*

### ភេទ

**A** man *បុរស* , boys *កុមារា* និង male animal *សត្វឈ្មោល* ជា masculine *បុំលិង្គ។*

- women *ស្ត្រី* , girls *កុមារី* និង female animal *សត្វញី* ជា feminine *ឥត្ថីលិង្គ។*

វត្ថុ រុក្ខជាតិ សត្វ ដែលយើងមិនស្គាល់ភេទ និង ជួនកាលទារកដែលយើងពុំស្គាល់ភេទរបស់វាជា អលិង្គ (សព្វនាម: *it/they*)លើកលែង: ប្រទេស នាវា រថយន្ត និង យានជំនិះ ផ្សេងទៀតជាឥត្ថីលិង្គ។

**B** នាមភាគច្រើនដែលនិយាយពីមនុស្សមានទំរង់ដូចគ្នា ទោះបីវាជាបុំលិង្គ ឬ ឥត្ថីលិង្គក៏ដោយ:

*baby ទារក child កុមារ cook ចុងភៅ doctor វេជ្ជបណ្ឌិត driver អ្នកបើកបរ parent ឪពុកម្តាយ teenager យុវជន*

- ប៉ុន្តែមួយចំនួនតូចមានទំរង់ខុសគ្នា។ នេះជាឧទាហរណ៍

*boy ក្មេងប្រុស, girl ក្មេងស្រី brother បងប្អូនប្រុស , sister បងប្អូនស្រី*
*uncle ពូ/អ៊ុំប្រុស, aunt មីង/អ៊ុំស្រី bridegroom កូនកំលោះ, bride កូនក្រមុំ*
*father ឪពុក, mother ម្តាយ actor សិល្បករ, actress សិល្បការិនី husband ប្តី*
*wife ប្រពន្ធ nephew ក្មួយប្រុស, niece ក្មួយស្រី king ស្តេចប្រុស, queen ស្តេចស្រី*
*widower ពោះម៉ាយ, widow មេម៉ាយ son កូនប្រុស , daughter កូនស្រី*
*waiter អ្នកបំរើប្រុស, waitress អ្នកបំរើស្រី*

**C** សត្វស្រុក និង សត្វព្រៃធំៗមួយចំនួនមានទំរង់ខុសៗគ្នាចំពោះបុំលិង្គ និង ឥត្ថីលិង្គ។

*bull គោឈ្មោល , cow គោញី cock មាន់ឈ្មោល hen មាន់ញី dog ឆ្កែឈ្មោល,*
*bitch ឆ្កែញី lion តោឈ្មោល , lioness តោញី tiger ខ្លាឈ្មោល, tigress ខ្លាញី*

### Exercise

- ចូររកនាមដែលមានទំរង់ឥត្ថីលិង្គខុសគ្នាហើយសរសេរទាំងឥត្ថីលិង្គនោះ:

| | | | | | |
|---|---|---|---|---|---|
| ☐ | *actor* | *actress* | | | |
| 1 | driver | 9 | waiter | 17 | host |
| 2 | elephant | 10 | camel | 18 | snake |
| 3 | guide | 11 | manager | 19 | player |
| 4 | son | 12 | uncle | 20 | brother-in-law |
| 5 | bull | 13 | lion | 21 | bridegroom |
| 6 | nephew | 14 | bachelor | 22 | doctor |
| 7 | cousin | 15 | widower | 23 | secretary |
| 8 | dog | 16 | assistant | 24 | teacher |

វិទ្យាស្ថាន វិទ្យាសាស្ត្រអាស៊ី THE ASIA INSTITUTE OF SCIENCES
វិទ្យាស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអូស្ត្រាលី THE AUSTRALIAN INSTITUTE FOR SCIENCE AND TECHNOLOGY
សាលារៀន អន្តរជាតិអូស្ត្រាលី The Australian International School
ណេក្សគ្រី NEKRY សាលារៀន ណេក្សគ្រី អន្តរជាតិ International School

## Session 2: Nouns នាម

### ទំរង់ពហុវចនៈទូទៅ

**A** យើងបង្កើតពហុវចនៈនៃនាមភាគច្រើនដោយបន្ថែម s ទៅអោយឯកវចនៈ
*cat ឆ្មា , cats day ថ្ងៃ , days dog ឆ្កែ , dogs change បំលាស់ប្តូរ , changes*

- *s* ត្រូវបានអានបញ្ចេញសំលេង /s/ ក្រោយ *f, k, p* ឬ *t* ប៉ុន្តែអាន /z/ ក្រោយសូរសំលេងផ្សេងទៀត។ កាលណា *s* បានត្រូវដាក់ពីក្រោយ *ce, ge, se* ឬ *ze* នោះបានត្រូវអាន /iz/។
*change* /tʃeindz/ ទៅជា *changes* /tfeindziz/

**B** យើងបង្កើតពហុវចនៈនៃនាមដែលបញ្ចប់ដោយ *ch, o, sh, s* or *x* ដោយបន្ថែម *es:*
church ព្រះវិហារ, churches brush ច្រាស, brushes box ប្រអប់, boxes
tomato ប៉េងប៉ោះ, tomatoes bus ឡានក្រុង, buses

- *es* ស្ថិតនៅក្រោយ *ch, sh, s* ឬ *x* បានត្រូវអាន /iz/: *buses* /bʌʃɪʒ/។

### Exercise

‣ ចូរសរសេរទំរង់ពហុវចនៈនៃនាមតទៅនេះ:

| | | | | | | | |
|---|---|---|---|---|---|---|---|
| ☐ | *watch* | | *watches* | | | | |
| 1 | box | 3 | case | 5 | day | 7 | tax |
| 2 | bus | 4 | cliff | 6 | match | 8 | tomato |
| 9 | bush | 10 | clock | 11 | potato | 12 | kiss |

### ទំរង់ពហុវចនៈប្លែកប្លែ

**A** នាមបញ្ចប់ដោយ ព្យញ្ជនៈ +*y* ត្រូវប្តូរ *y* ជា *ies*
*baby* ទារក, *babies country* ប្រទេស , *countries fly* រុយ, *flies lady* ស្ត្រី, *ladies*

**B** នាមមួយចំនួនបញ្ចប់ដោយ *o* បន្ថែម *s*
*kilo* គីឡូ , *kilos photo* រូបថត, *photos piano* ព្យាណូ ,*pianos*
*radio* វិទ្យុ , *radios*

**C** នាមមួយចំនួនបញ្ចប់ដោយ *f* ឬ *fe* ប្តូរជា *ves*
*half* ពាក់កណ្តាល , *halves life* ជីវិត, *lives shelf* ធ្នើរ, *shelves wife* ប្រពន្ធ , *wives*

- ក្រៅពីនេះមាន *calf* កោន , *knife* កាំបិត, *leaf* ស្លឹកឈើ, *loaf* នំបុ័ង, *thief* ចោរ , *wolf* ឆ្កែចចក។

**D** នាមបីបួន បង្កើតទំរង់ពហុវចនៈដោយប្តូរស្រៈ:
*foot* ជើង, *feet man* បុរស, *men tooth* ធ្មេញ, *teeth woman* ស្ត្រី , *women*

**E** ពហុវចនៈ *child* កុមារ គឺ *children*

**F** នាមមួយចំនួនពុំផ្លាស់ប្តូរសោះក្នុងទំរង់ពហុវចនៈ:
*aircraft* យន្តហោះ *deer* ក្តាន់ *series* ស៊េរី *sheep* ចៀម *fish* ត្រី ជាធម្មតាពុំផ្លាស់ប្តូរទេ, ប៉ុន្តែ *fishes* ក៏អាចប្រើបានដែរ។

### Exercise

‣ ចូរសរសេរទំរង់ពហុវចនៈនៃនាមទាំងនេះ

| | | | | | | | |
|---|---|---|---|---|---|---|---|
| ☐ | *knife* | *knives* | | | | | |
| 1 | baby | 6 | key | 11 | man | 16 | storey |
| 2 | child | 7 | kilo | 12 | photo | 17 | story |
| 3 | country | 8 | woman | 13 | piano | 18 | thief |
| 4 | aircraft | 9 | leaf | 14 | sheep | 19 | tooth |
| 5 | foot | 10 | loaf | 15 | shelf | 20 | wife |

### ពហុវចនៈនៃនាមសមាស

**A** ជាធម្មតានៅក្នុងនាមសមាសមានតែពាក្យចុងក្រោយប៉ុណ្ណោះដែលត្រូវដាក់ជាពហុវចនៈ:
*boy-friends* មិត្តប្រុស *break-ins* ការសំរុកចូល *travel agents* ភ្នាក់ងារទេសចរ
*ladydoctors* វេជ្ជបណ្ឌិតពិនិត្យស្ត្រី

- ប៉ុន្តែបើ *man* ឬ *woman* ជាពាក្យទីមួយនោះពាក្យទាំងពីរត្រូវដាក់ជាពហុវចនៈ។

***men*** *driver**s*** *អ្នកបើកបរបុរស* ***women*** *teacher**s*** *គ្រូបង្រៀនស្រី*

- ពាក្យទីមួយត្រូវដាក់ជាពហុវចនៈក្នុងសមាសភាព " នាម + អយតនិបាត + នាម "

*sister**s**-in-law* *បងប្អូនស្រីថ្លៃ* *ladie**s**-in-waiting* *ស្ត្រីរងចាំទទួលភ្ញៀវ*

- និងក្នុង

*hanger**s**-on* *ប្រដាប់ព្យួរអីវ៉ាន់* *looker**s**-on* *ស្ត្រីគួរឱ្យចាប់អារម្មណ៍*

**B** អក្សរកាត់អាចដាក់ជាពហុវចនៈដោយបន្ថែម *s* នៅខាងចុង

***MPs*** (Members of Parliament) សមាជិកសភា

***VIPs*** (very important persons) ឥស្សរៈជន

## Exercise

- ចូរសរសេរទម្រង់ពហុវចនៈនៃនាមទាំងនេះ

| | | | | |
|---|---|---|---|---|
| ☐ | *girl-friend* | | *girl-friends* | |
| 1 | brother-in-law | 4 | lady doctor | 7 time bomb |
| 2 | house agent | 5 | MP | 8 woman driver |
| 3 | juke-box | 6 | runner-up | |

## ពហុវចនៈឬឯកវចនៈ

**A** នាមមួយចំនួនជាពហុវចនៈជានិច្ចហើយច្រើនជាកិរិយាស័ព្ទពហុវចនៈ

*arms* (= weapons អាវុធ) *greens* *បៃតង* *savings* *ប្រាក់សន្សំ*
*clothes* *សំលៀកបំពាក់* *police* *នគរបាល* *stairs* *ជណ្តើរ*
*earnings* *ប្រាក់សន្សំ* *premises* *អចលនវត្ថុ* *quarters* *សង្កាត់*
*surroundings* *បរិយាកាស* *goods* *ទំនិញ* *riches* *ទ្រព្យ* *thanks* *អំណរគុណ*

- ដូចគ្នាដែរចំពោះ *clothes* *សំលៀកបំពាក់instruments* *ឧបករណ៍* .......។ល។ ដែលមានពីរផ្នែក:

*glasses* *វ៉ែនតា* *pants* *ខោជើងខ្លី* *scales* *ជញ្ជីង* *tights* *ខោ*
*jeans* *ខោខូវប៊ិយ* *pyjamas* *អាវដំណេក* *scissors* *កន្ត្រៃ* *trousers* *ខោជើងវែង*

**B** នាមមួយចំនួនតែងតែមានទម្រង់ជាពហុវចនៈ ប៉ុន្តែត្រូវការកិរិយាស័ព្ទពហុវចនៈ ឬ ឯកវចនៈ:

*works* (= factory) រោងចក្រ *headquarters* *អគ្គសេនាធិការ*
*politics* *នយោបាយ* *means* *មធ្យោបាយ*
*mathematics* *គណិតវិទ្យា* *athletics* *អត្តពលកម្ម*

**C** ដំណឹងនិងឈ្មោះនៃល្បែងនិងជំងឺមួយចំនួនតែងតែមានទម្រង់ពហុវចនៈ ប៉ុន្តែ តែងតែត្រូវការកិរិយាស័ព្ទឯកវចនៈ:

*The **news is** on television at nine o'clock.*
*ពត៌មាននឹងបញ្ចាំងតាមទូរទស្សន៍នៅម៉ោងប្រាំបួន។*
***Measles is** not usually a fatal disease.*
*ជម្ងឺកញ្ជ្រិលពុំមែនជាជម្ងឺបណ្តាលអោយស្លាប់ទេ។*

**D** សមូហនាមឯកវចនៈ (*government* *រដ្ឋាភិបាល* *crew* *បុគ្គលិក* *family* *គ្រួសារ* *team* *ក្រុម*......។ល។ ) អាចប្រើជាមួយនាមឯកវចនៈ ឬ ពហុវចនៈ:

*Our **team is** the best. ក្រុមរបស់យើងជាក្រុមពូកែបំផុត* (ក្រុមមានតែមួយគត់)។
*Our **team are** wearing new T-shirts. ក្រុមរបស់យើងកំពុងពាក់អាវយឺតថ្មី។*
(ក្រុមជាចំនួនមនុស្សនីមួយៗ)

**E** នាមពុំអាចរាប់បានជាឯកវចនៈនិងត្រូវប្រើជាមួយកិរិយាស័ព្ទឯកវចនៈ

## Exercise

- ចូរជ្រើសរើសទម្រង់កិរិយាស័ព្ទត្រឹមត្រូវឯកវចនៈឬពហុវចនៈ

☐ The police **is/*are*** are watching the house.
1 His trousers **is/are** too long.
2 Rabies **is/are** a very dangerous disease.
3 The news **was/were** better today.
4 The stairs **leads/lead** to the cellar.